សលាកប័ត្រព័ត៌មាន ៖ កម្រងឯកសារស្តីពីស្ថាប័ន ៖ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (“គ.ជ.ប”)

ស្ថាប័ន ៖ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

រូបភាពរួម ៖ ស្ថាប័នត្រួតពិនិត្យការបោះឆ្នោតដែលមានសមត្ថកិច្ច អព្យាក្រិត និងឯករាជ្យ ហើយមានសមត្ថភាពដោះស្រាយបណ្តឹងប្រកបដោយប្រសិទ្ធិភាព មានសារៈសំខាន់ណាស់ក្នុងការផ្តល់ទំនុកចិត្តដល់អ្នកបោះឆ្នោតលើនីតិវិធីបោះឆ្នោត ។ ទោះជាយ៉ាងណាក៏ដោយ បញ្ហាពាក់ព័ន្ធនឹងរចនាសម្ព័ន្ធ ឯករាជ្យភាព និងការប្រព្រឹត្តទៅរបស់គ.ជ.ប បានចោទជាសំណួរទាក់ទងនឹងលទ្ធភាពរបស់គ.ជ.ប ក្នុងតួនាទីជាស្ថាប័នត្រួតពិនិត្យការបោះឆ្នោតមួយដែលជាក់លាក់ និងប្រកបដោយយុត្តិធម៌ ។

សេចក្តីផ្តើម

មុនពេលបោះឆ្នោតឃុំសង្កាត់ដែលនឹងប្រព្រឹត្តទៅឆាប់ៗនេះនាថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១២ និងបោះឆ្នោតជាតិនាឆ្នាំក្រោយ សលាកប័ត្រព័ត៌មាននេះ ពន្យល់អំពីតួនាទី និងសមាសភាពរបស់គ.ជ.ប ព្រមទាំងបញ្ហាពាក់ព័ន្ធនឹងសមត្ថភាពរបស់ស្ថាប័ននេះ ក្នុងការដោះស្រាយបណ្តឹងប្រកបដោយប្រសិទ្ធិភាព មុននឹងផ្តល់អនុសាសន៍ដើម្បីកែលម្អ ។ សលាកប័ត្រព័ត៌មាននេះ សរសេរឡើងដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ដែលជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ មិនចូលបក្សសម្ព័ន្ធ ធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ជាពិសេស សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅព្រះរាជាណាចក្រកម្ពុជា (“កម្ពុជា”) ។

តើគ.ជ.ប ជាអ្វី?

គ.ជ.ប គឺជាស្ថាប័នត្រួតពិនិត្យការបោះឆ្នោតដ៏សំខាន់មួយក្នុងប្រទេសកម្ពុជា ដែលមានយុត្តាធិការត្រួតពិនិត្យការបោះឆ្នោតសមាជិកសភា និងក្រុមប្រឹក្សាឃុំសង្កាត់ ព្រមទាំងការបោះឆ្នោតសមាជិកព្រឹទ្ធសភាដែលមានលក្ខណៈអសកល និងការបោះឆ្នោតក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក និងខណ្ឌ ។ ដើម្បីបំពេញអាណត្តិរបស់ខ្លួន គ.ជ.ប មានស្ថាប័នបោះឆ្នោតនៅពាសពេញផ្ទៃប្រទេសនៅគ្រប់ថ្នាក់រដ្ឋបាល ខេត្ត ក្រុង និងឃុំទាំងអស់ ។ គ.ជ.ប ទទួលបន្ទុកក្នុងការធ្វើគម្រោង រៀបចំ និងត្រួតពិនិត្យការបោះឆ្នោត រួមមានការប្រកាសលទ្ធផលបោះឆ្នោត បង្កើត និងចែកចាយឯកសារអប់រំប្រជាពលរដ្ឋ ការត្រួតពិនិត្យប្រព័ន្ធផ្សព្វផ្សាយ ការចុះបញ្ជីឈ្មោះអ្នកបោះឆ្នោត និងគណបក្សនយោបាយ ។ គ.ជ.ប ក៏ទទួលបន្ទុកផ្នែកបណ្តឹង និងឧទ្ធរដែលពាក់ព័ន្ធនឹងការបោះឆ្នោតទាំងអស់ផងដែរ ។

សមាសភាពរបស់គ.ជ.ប

គ.ជ.ប មានសមាជិកចំនួនប្រាំបួននាក់ ។ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសសមាជិកសភាកំណត់ថា គ.ជ.ប គឺជា “*ស្ថាប័នឯករាជ្យ និងអព្យាក្រិត*” ហើយបញ្ជាក់ថា “*ក្នុងការអនុវត្តតួនាទីរបស់ខ្លួន សមាជិករបស់ [គ.ជ.ប] និងគណៈកម្មាការរៀបចំការបោះឆ្នោតនៅគ្រប់ថ្នាក់ទាំងអស់ ត្រូវប្រកាន់យកអព្យាក្រិតភាព និងអនាគតិក្នុងការអនុវត្តតួនាទីរៀបចំការបោះឆ្នោតរបស់ពួកគេ*” ។ សមាជិក គ.ជ.ប ត្រូវបានជ្រើសរើសដោយក្រសួងមហាផ្ទៃ (“ក.ម.ផ”) នឹងតែងតាំងដោយព្រះរាជក្រឹត្យតាមសំណូមពររបស់គណៈរដ្ឋមន្ត្រី បន្ទាប់ពីមានការឯកភាពពីសមាជិកច្រើនដាច់ខាតក្នុងរដ្ឋសភា ។ ពួកគេត្រូវបានតម្រូវឲ្យបោះបង់ទំនាក់ទំនងជាមួយនឹងគណបក្សនយោបាយ ។ ដាច់ដោយឡែកពីក្រសួងមហាផ្ទៃ គ.ជ.ប ទទួលថវិកាពីក្រសួងពាណិជ្ជកម្ម ដែលនេះដកហូតនូវអំណាចគ្រប់គ្រងមូលនិធិដោយខ្លួនឯង និងអាចឲ្យរងឥទ្ធិពលពីស្ថាប័ននីតិប្រតិបត្តិ ។ អាណត្តិរបស់សមាជិកគ.ជ.ប មិនត្រូវបានកំណត់ និងមិនមានការការពារប្រឆាំងនឹងការដកសមាជិកចេញពីគ.ជ.ប តាមអំពើចិត្តឡើយ ។

ការប្រព្រឹត្តទៅរបស់គ.ជ.ប

ទោះបីជាច្បាប់តម្រូវឲ្យសមាជិកគ.ជ.ប ត្រូវមានឯករាជ្យភាពក៏ដោយ ពួកគេត្រូវជ្រើសរើសប្រកបដោយប្រសិទ្ធិភាពដោយស្ថាប័នដែលជ្រើសរើសដោយរាជរដ្ឋាភិបាល (“រ.ដ.ក”) ក្នុងពេលបច្ចុប្បន្ននេះ ដែលនេះចោទឡើងជាសំណួរទាក់ទងនឹងឯករាជ្យភាពពិតប្រាកដរបស់គ.ជ.ប ។ មនុស្សភាគច្រើនចាត់ទុកថាភាពមិនប្រក្រតីនេះមានលក្ខណៈគួរឲ្យកត់សម្គាល់ នៅពេលមានការជំនុំជំរះពាក្យបណ្តឹងដែលគ.ជ.ប ធ្វើឡើងចំពោះការបំពានលើច្បាប់បោះឆ្នោត ។ សេចក្តីសម្រេចដែលគ.ជ.ប បានប្រកាស មិនមានលក្ខណៈស្របច្បាប់ក្នុងការរារាំងតុលាការពីការផ្តន្ទាទោសព្រហ្មទណ្ឌឡើយ ប្រសិនបើពាក្យបណ្តឹងដូចគ្នានេះ ត្រូវបានបញ្ជូនទៅតុលាការ ។ បណ្តឹងមួយចំនួនអាចដាក់នៅថ្នាក់មូលដ្ឋាន ចំពោះករណីបណ្តឹងដែលបានបញ្ជូនទៅកាន់គ.ជ.ប ដែលជាបណ្តឹងឧទ្ធរពីរដ្ឋបាលថ្នាក់ក្រោម ឬអាចបញ្ជូនទៅកាន់គ.ជ.ប ដោយផ្ទាល់ ប្រសិនបើបណ្តឹងនោះប្តឹងប្រឆាំងនឹងរដ្ឋបាលថ្នាក់ក្រោម ។

យោងតាមស្ថិតិរបស់គ.ជ.ប ក្នុងឆ្នាំ២០១០ ក្នុងចំណោមពាក្យបណ្តឹងទាំង២២ទាក់ទងនឹងការបោះឆ្នោតដែលគ.ជ.ប ទទួលបានក្នុងឆ្នាំ២០១០ បណ្តឹងចំនួន១៣ត្រូវបានច្រានចោល និងបណ្តឹង៩ទៀតបានដោះស្រាយក្នុងថ្នាក់ឃុំ ។ បណ្តឹងទាំងនេះពាក់ព័ន្ធនឹង

ស្មៀនឃុំ ដែលចុះឈ្មោះអ្នកបោះឆ្នោតដោយគ្មានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ពីអត្តសញ្ញាណ ឈ្មោះរបស់អ្នកបោះឆ្នោតមិនមានក្នុងបញ្ជីឈ្មោះបោះឆ្នោត និងមន្ត្រីឃុំលុបឈ្មោះអ្នកបោះឆ្នោតចេញពីបញ្ជីឈ្មោះបោះឆ្នោត ។

ទោះបីជាយ៉ាងណាក៏ដោយ ក្នុងកំឡុងពេលបោះឆ្នោត និងបន្ទាប់ពីពេលបោះឆ្នោត គេមិនឃើញមានដំណើរការប្តឹងឧទ្ធរដែលមានលក្ខណៈទូលំទូលាយឡើយ ហើយដំណើរការដែលមានស្រាប់នោះទៀតសោត នៅមានភាពខ្វះចន្លោះនៅឡើយ ។ ឧទាហរណ៍ បណ្តឹងដែលពាក់ព័ន្ធនឹងការបោះឆ្នោត ឬការរាប់សន្លឹកឆ្នោតទាក់ទងនឹងការបោះឆ្នោតជាតិ ត្រូវដាក់មុនម៉ោង១១និង៣០ នាទីព្រឹកនៅថ្ងៃបន្ទាប់ពីថ្ងៃបោះឆ្នោត ។ បណ្តឹងពាក់ព័ន្ធនឹងអាកប្បកិរិយាមិនសមរម្យរបស់មន្ត្រី ត្រូវដាក់ក្នុងរយៈពេលបីថ្ងៃបន្ទាប់ពីព្រឹត្តការណ៍នោះកើតឡើង ។ ហេតុដូច្នេះហើយ ពេលវេលាសម្រាប់ការដាក់បណ្តឹងមិនមានលក្ខណៈគ្រប់គ្រាន់សម្រាប់ភាគីដែលចង់ដាក់ពាក្យបណ្តឹងដើម្បីប្រមូលភស្តុតាង ដែលពួកគេភាគច្រើនជាអ្នកគាំទ្រគណបក្សប្រឆាំង ។ ជាលទ្ធផល បណ្តឹងត្រូវបានគេច្រានចោលជាប្រចាំ ។

កំណែទម្រង់ស្ថាប័នត្រួតពិនិត្យការបោះឆ្នោត

ស្ថាប័នត្រួតពិនិត្យការបោះឆ្នោតដែលមានសមត្ថកិច្ច អព្យាក្រិត និងឯករាជ្យ ហើយមានសមត្ថភាពដោះស្រាយបណ្តឹងប្រកបដោយប្រសិទ្ធិភាព មានសារៈសំខាន់ណាស់ក្នុងការផ្តល់ទំនុកចិត្តដល់អ្នកបោះឆ្នោតលើនីតិវិធីបោះឆ្នោត ។ នៅពេលដែលប្រទេសកម្ពុជានឹងទៅបោះឆ្នោតនៅថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១២ ប្រជាពលរដ្ឋត្រូវមានទំនុកចិត្តលើយន្តការត្រួតពិនិត្យ ។ បើមិនដូច្នោះទេ ពួកគេនឹងមិនទំនងជាទៅបោះឆ្នោតឡើយ ។ ទំនុកចិត្តនេះតម្រូវឲ្យមានគ.ជ.ប ដែលមានប្រសិទ្ធិភាព និងមានការគោរពពីប្រជាពលរដ្ឋ ។ កំណែទម្រង់នីតិវិធីបណ្តឹងនៃស្ថាប័នត្រួតពិនិត្យការបោះឆ្នោតទាំងអស់ ត្រូវរួមបញ្ចូលទាំងការផ្លាស់ប្តូរចនាសម្ព័ន្ធផ្ទៃកច្បាប់របស់ស្ថាប័ន ។ ប្រសិនបើគ្មានសកម្មភាពបែបនេះទេ ការផ្លាស់ប្តូរទាក់ទងនឹងការត្រួតពិនិត្យនឹងគ្មានប្រយោជន៍អ្វីឡើយ ប្រសិនបើស្ថាប័នត្រួតពិនិត្យការបោះឆ្នោត ត្រូវបានអ្នកបោះឆ្នោតគិតថាកង្វះអព្យាក្រិតភាព និងអនាគតិ ។ ហេតុដូច្នេះហើយ អនុសាសន៍សម្រាប់កំណែទម្រង់គ.ជ.ប មានដូចខាងក្រោម ៖

- ដំណើរការជ្រើសរើសដែលបើកចំហមួយ ដែលតម្រូវឲ្យមានគណបក្ស និងសមាជិកកាន់តែច្រើនក្នុងគ.ជ.ប និងស្ថាប័នត្រួតពិនិត្យការបោះឆ្នោតមានសារសំខាន់ណាស់ ។ ឧទាហរណ៍ សមាជិកអាចរួមមានអ្នកជំនាញផ្ទៃកអប់រំ អ្នកវិភាគនយោបាយ មេធាវី ។ ល ។ ជាជាងមានត្រឹមតែអ្នកនយោបាយ ។ វិធីសាស្ត្រនេះ អាចបណ្តុះឲ្យមានកម្រិតចាំបាច់មួយនៃឯករាជ្យភាព និងអព្យាក្រិតភាពក្នុងការធ្វើសេចក្តីសម្រេចរបស់គ.ជ.ប និងបង្កើនទំនុកចិត្តរបស់អ្នកបោះឆ្នោតចំពោះគ.ជ.ប ។

- សន្តិសុខនៃអាណត្តិរបស់សមាជិកគ.ជ.ប និងអវត្តមាននៃការដកចេញសមាជិកតាមអំពើចិត្ត នឹងផ្តល់ទំនុកចិត្តដល់សមាជិកគ.ជ.ប ក្នុងការបំពេញកិច្ចការដែលខ្លួនទទួលខុសត្រូវ ដោយមិនមានការភ័យខ្លាចចំពោះការដកចេញពីដំណែង និងកំណត់សក្តានុពលក្នុងការគ្រប់គ្រង ។ ការធ្វើវិសោធនកម្មបទបញ្ជារបស់គ.ជ.ប ដើម្បីចៀសវាងសមាជិកមិនឲ្យបម្រើប្រយោជន៍របស់គណបក្សនយោបាយ បន្ទាប់ពីចាកចេញពីគ.ជ.ប ភ្លាមៗនោះ នឹងធានាថាសមាជិកនឹងមិនទទួលឥទ្ធិពលខ្លាំងពីនយោបាយឡើយ ។

- ក្នុងផ្ទៃកមួយនៃកិច្ចខិតខំប្រឹងប្រែងដើម្បីលើកម្ពស់ឯករាជ្យភាព និងអនាគតិរបស់គ.ជ.ប រដ្ឋសភាត្រូវធ្វើការផ្លាស់ប្តូរចាំបាច់ដើម្បីឲ្យគ.ជ.ប ទទួលបានគោលការណ៍ថវិកាស្របច្បាប់ និងឯករាជ្យ ។

- រ.ដ.ក និងរដ្ឋសភាត្រូវធ្វើវិសោធនកម្មច្បាប់ ដើម្បីកែប្រែកាលបរិច្ឆេទផុតកំណត់ និងនីតិវិធីក្នុងការដាក់ពាក្យបណ្តឹងបន្ទាប់ពីការបោះឆ្នោត ដើម្បីផ្តល់ពេលវេលាគ្រប់គ្រាន់ដល់អ្នកដែលចង់ដាក់ពាក្យបណ្តឹង ក្នុងការប្រមូលភស្តុតាងគាំទ្របណ្តឹងរបស់ពួកគេ ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង លោក អ៊ូ វីរៈ: (+៨៥៥ (0) ១២ ៤០ ៤០ ៥១ ឬអ៊ីម៉ែល៖ ouvirak@cchrcambodia.org **ឬកញ្ញា សាណា ហ្គោស (+៨៥៥ (0) ៨៩ ៦១ ៥៣ ៣៥ ឬអ៊ីម៉ែល៖** sana.ghouse@cchrcambodia.org **។**

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights